# ពុទ្ធដំណើរត្រាស់ដឹង

# និង

# ធម្មចក្កប្បវត្តនសូត្រ

*រៀបរៀងដោយ*

**ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន**

*ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*ព.ស.២៥៥៣*

| | |
|---|---|
| ឈ្មោះសៀវភៅ | ពុទ្ធដំណើរត្រាស់ដឹង និងធម្មចក្កប្បវត្តនសូត្រ |
| រៀបរៀងដោយ | ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន អគ្គលេខាធិការ<br>នៃពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃ អង្គារ ១៥ កើតពេញបូណ៌មី ខែអាសាឍ ព.ស.<br>២៥៥៣ ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩ |
| បោះពុម្ពដោយ | ពុទ្ធបរិស័ទទូទៅ |
| បោះពុម្ពចំនួន | ១,០០០ ក្បាល |

## អារម្ភកថា

ថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍ ជាថ្ងៃពិសេសមួយក្នុងព្រះពុទ្ធសាសនា ៖

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់យាងចុះចាប់បដិសន្ធិ

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់យាងសាងព្រះផ្នួស

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រកាសសម្តែងបឋមទេសនា គឺធម្មចក្កប្បវត្តនសូត្រ ដែលជាធម្មរតនៈក្នុងលោក

-ជាថ្ងៃព្រះសង្ឃរតនៈកើតឡើងក្នុងលោក

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងយមកបាដិហារ្យក្នុងក្រុងសាវត្ថី ។

អាស្រ័យហេតុនេះហើយ ទើបពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា ដែលមានលោកបណ្ឌិត **គុល ផេង** ជាប្រធានក្រុមប្រឹក្សាភិបាល បានព្រមព្រៀងគ្នាបង្កើតនូវកម្មវិធីជួបជុំព្រះសង្ឃ និងពុទ្ធបរិស័ទស្វាធ្យាយ និងធម្មសាកច្ឆាក្នុងធម្មចក្កប្បវត្តនសូត្រ នៅថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍ ឆ្នាំ ឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩ ។

កម្មវិធីនេះប្រារព្ធឡើង ដើម្បីរំលឹកដល់ព្រះធម្មរតនៈ និងព្រះសង្ឃរតនៈ ដែលកើតមានក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍនេះ ។

ចិរំ សទ្ធម្មោ តិដ្ឋតុ

*សូមព្រះសទ្ធម្មតាំងនៅអស់កាលដ៏យូរ!*

សព្វេ សត្តា អវេរិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ កុំមានពៀរនឹងគ្នា*

សព្វេ សត្តា ខេមិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ បានដល់នូវសេចក្តីក្សេម*

សព្វេ សត្តា សុខិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយបានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ៍!*

*ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥៣*

*ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩*

**ជម្នាណឆ្នុ ច៊ាន់ ចាន់សារ៉ែន**

*អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

## សម្ភោធនីយកថា

ខ្ញុំព្រះករុណា ខ្ញុំបាទមានចិត្តរីករាយប្រកបដោយបីតិសោមនស្ស យ៉ាងខ្លាំង ចំពោះការប្រារព្ធពិធីបុណ្យអាសាឡ្ហបូជានេះ ។ ក្នុងកម្មវិធីនេះ ទៀតសោត មានការស្វាធ្យាយធម្មចក្កប្បវត្តនសូត្រ និងកម្មវិធីសន្ទនាព្រះធម៌ ដែលជាប់ទាក់ទងក្នុងធម្មចក្កប្បវត្តនសូត្រ ។ នេះជាប្រវត្តិសាស្ត្រទី ១ សម្រាប់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលមានខ្ញុំព្រះករុណា ខ្ញុំបាទ ជាប្រធានក្រុមប្រឹក្សាភិបាល ។ ខ្ញុំព្រះករុណា ខ្ញុំបាទសង្ឃឹមមាំថា ពុទ្ធិកបណ្ឌិតសភានឹងរៀបចំនូវកម្មវិធីនេះ រៀងរាល់ឆ្នាំក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍ ដើម្បីជួបជុំព្រះសង្ឃ និងពុទ្ធបរិស័ទស្វាធ្យាយធម្មចក្កប្បវត្តនសូត្រ ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងអំណរអរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅ ចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងពុទ្ធសាសនិកជនគ្រប់រូប ដែលបានគាំទ្រនិងជួយឧបត្ថម្ភនូវកម្មវិធីរបស់ពុទ្ធិកបណ្ឌិតសភានៃសាកវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ។

ដោយគុណានុភាពនៃព្រះរតនត្រ័យ សូមព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទជួបប្រសព្វនូវធម៌ដ៏ប្រសើរគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥៣

ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩

**បណ្ឌិត ក្រុល ផេង**

ប្រធានក្រុមប្រឹក្សាភិបាលនៃពុទ្ធិកបណ្ឌិតសភា